ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៤៣០ សហវ.ប្រក

ថ្ងៃ ចន្ទ ៥កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៩

# ប្រកាស
# ស្តីពី
# ការផ្ទេរឥណទានថវិកា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃ សុក្រ ០៩រោច ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃ សុក្រ ០២កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០
- បានឃើញអនុក្រឹត្យលេខ ២៤១ អនក្រ.បក ចុះថ្ងៃ សុក្រ ០២កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីការផ្ទេរឥណទានថវិកា
- តាមការចាំបាច់ដើម្បីអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១ .-**

ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល ក្រសួង-សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ នូវការផ្ទេរឥណទានថវិកាដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម៖

**ក-និយ័តកម្មចេញពី ៩៩ (ចំណាយមិនទាន់បែងចែកមានមុខសញ្ញា)**

ឯកតា៖ លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិ. ឆ្នាំ ២០២០ | ឥណទានមុន និយ័តកម្ម | និយ័តកម្ម | | ឥណទានថ្មីក្រោយ និយ័តកម្ម |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | <u>និយ័តកម្មចេញ</u> | | | | <u>**2.733.852**</u> | |
| | | | ៩៩-ចំណាយមិនទាន់បែងចែកមានមុខសញ្ញា | | | | **2.733.852** | |
| 66 | | | បន្ទុកហិរញ្ញវត្ថុ | 542.077 | 542.077 | - | 542.077 | 0 |
| 65 | | | ឧបត្ថម្ភរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ | 1.085.458 | 1.085.458 | - | 1.085.458 | 0 |
| 69 | 6901 | 69011 | ចំណាយមិនបានគ្រោងទុក | 788.884 | 788.884 | - | 395 | 788.489 |
| 50 | | | មានមុខសញ្ញាច្បាស់លាស់ ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល | 1.105.922 | 1.105.922 | - | 1.105.922 | 0 |
| | | | <u>និយ័តកម្មចូល</u> | | | <u>**2.733.852**</u> | | |
| | | | ១០-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | | **2.733.852** | | |
| 66 | | | បន្ទុកហិរញ្ញវត្ថុ | - | - | 542.077 | | 542.077 |
| 65 | 6501 | 65011 | ឧបត្ថម្ភធនដល់រាជធានី-ខេត្ត | - | - | 47.024 | | 47.024 |
| 65 | 6501 | 65012 | ឧបត្ថម្ភធនដល់ក្រុង-ស្រុក-ខណ្ឌ | - | - | 235.117 | | 235.117 |
| 65 | 6501 | 65013 | ឧបត្ថម្ភធនដល់ឃុំ-សង្កាត់ | - | - | 803.712 | | 803.712 |
| 50 | | | ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល | - | - | 1.105.922 | | 1.105.922 |

**ខ-និយ័តកម្មចេញពីក្រសួងសុខាភិបាល**

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិ. ឆ្នាំ ២០២០ | ឥណទានមុន និយ័តកម្ម | និយ័តកម្ម | | ឥណទានថ្មីក្រោយ និយ័តកម្ម |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | <u>និយ័តកម្មចេញ</u> | | | | <u>**30.000**</u> | |
| | | | ១២-ក្រសួងសុខាភិបាល (កម្មវិធីទី ៤ អនុកម្មវិធីទី ១ ចង្កោមសកម្មភាពទី ១៨ | | | | **30.000** | |
| 62 | 6202 | 62028 | ជំនួយសង្គមផ្សេងៗទៀត | 136.000 | 136.000 | - | 30.000 | 106.000 |

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិ.រ. ឆ្នាំ ២០២០ | ឥណទានមុន និយ័តកម្ម | និយ័តកម្ម | | ឥណទានថ្មីក្រោយ និយ័តកម្ម |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | **និយ័តកម្មចូល** | | | **30.000** | | |
| | | | ២១-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (កម្មវិធីទី ១ អនុកម្មវិធីទី ១ ចង្កោមសកម្មភាពទី ៣) | | | **30.000** | | |
| 60 | 6002 | 60021 | សម្ភារការិយាល័យ | - | - | 10 | - | 10 |
| 61 | 6105 | 61057 | ការថែទាំនិងជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេស | - | - | 40 | - | 40 |
| 61 | 6110 | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | - | - | 10,5 | - | 10,5 |
| 61 | 6110 | 61107 | ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ | - | - | 40 | - | 40 |
| 61 | 6112 | 61121 | សោហ៊ុយដឹកជញ្ជូនក្នុងប្រទេស | - | - | 50 | - | 50 |
| 61 | 6112 | 61122 | សោហ៊ុយបេសកកម្មក្នុងប្រទេស | - | - | 50 | - | 50 |
| 61 | 6112 | 61123 | សោហ៊ុយស្នាក់នៅក្នុងប្រទេស | - | - | 80 | - | 80 |
| 61 | 6114 | 61142 | សោហ៊ុយទូរគមនាគមន៍ | - | - | 30 | - | 30 |
| 61 | 6115 | 61151 | សោហ៊ុយធនាគារ | - | - | 814 | - | 814 |
| 62 | 6202 | 62028 | ជំនួយសង្គមផ្សេងៗទៀត | - | - | 28.875,5 | - | 28.875,5 |

**ប្រការ២ .-**

ឥណទានថវិកាដែលបានផ្ទេរក្នុងប្រការ ១ ខាងលើនេះ ត្រូវបានអនុញ្ញាតឱ្យបំពេញបន្ថែមទៅក្នុងសៀវភៅថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០។

**ប្រការ៣ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូនៈ**
- អគ្គនាយកដ្ឋានរតនាគារជាតិ
- អគ្គនាយកដ្ឋាន/នាយកដ្ឋានពាក់ព័ន្ធ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ